# កិច្ចព្រមព្រៀង

# ស្តីពី

# ការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

# រវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង អង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

( កិច្ចព្រមព្រៀងទទួលស្គាល់សុពលភាព )

**រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** (ដែលហៅកាត់ថា"កម្ពុជា") តំណាងដោយ ឯកឧត្តម បណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដែលហៅកាត់ថា "MIH"

និង

**ស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប** (ដែលហៅកាត់ថា "ស្ថាប័ន") តំណាងដោយ

លោក Benoît BATTISTELLI ប្រធានអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (ដែលហៅកាត់ថា "EPO" )

**អនុលោមតាម**

អនុសញ្ញាស្តីពីការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ចុះថ្ងៃទី៥ ខែតុលាឆ្នាំ ១៩៧៣ ដូចមានការកែសម្រួលចុងក្រោយ ដោយច្បាប់ ស្តីពីវិសោធនកម្មនៃអនុសញ្ញាប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (EPC) ចុះថ្ងៃទី ២៩ខែវិច្ឆិកា ឆ្នាំ២០០០ (ហៅកាត់ថា "អនុសញ្ញាប្រកាសនីយបត្រតក្កកម្មអឺរ៉ុប") និងជាពិសេស មាត្រា ៣៣ (៤) នៃអនុសញ្ញានេះ។

តាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៣ របស់កម្ពុជា។

**ដោយពិនិត្យឃើញថា**

ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្មរបស់កម្ពុជា បានផ្តល់នូវកម្រិតនៃការការពារប្រហាក់ប្រហែលគ្នាទៅនឹងប្រកាសនីយបត្រតក្កកម្មដែលមាននៅក្នុង រដ្ឋជាសមាជិកនៃស្ថាប័ន។ លើកលែងតែការការពារប្រកាសនីយបត្រតក្កកម្ម ដែលទាក់ទងទៅនឹងផលិតផលឱសថ ដោយសារតែ ប្រទេសកម្ពុជាទទួលបានផលប្រយោជន៍ពីការលើកលែង របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលអនុញ្ញាតឱ្យ សមាជិកដែលជាប្រទេសអភិវឌ្ឍតិចតួចជ្រើសរើសការការពារ ឬមិនការពារផលិតផលឱសថដោយប្រកាសនីយបត្រតក្កកម្ម រហូតដល់ឆ្នាំ ២០៣៣។

កម្ពុជានឹងផ្តល់ប្រពន្ធ័មួយដែលអាចធ្វើឲ្យមានប្រសិទ្ធភាព នៃពាក្យសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងប្រកាសនីយបត្រតក្កកម្ម ដែលត្រូវមានសុពលភាព តាមការស្នើសុំនៅក្នុងទឹកដីរបស់ខ្លួន ដោយបញ្ចូលក្នុងក្របខណ្ឌច្បាប់ជាតិរបស់ខ្លួន នូវបទប្បញ្ញត្តិសម្រាប់អនុវត្ត ប្រព័ន្ធទទួលស្គាល់សុពលភាព (ដែលហៅកាត់ថា "ប្រព័ន្ធទទួលស្គាល់សុពលភាព")។

**ដោយហេតុថា** កម្ពុជាជាភាគីនៃសន្ធិសញ្ញា សហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម (PCT) ហើយបានជ្រើសរើស EPO ជាអាជ្ញាធរស្រាវជ្រាវអន្តរជាតិ និងពិនិត្យជំហានដំបូងអន្តរជាតិ ដែលស្ថិតនៅក្រោមសន្ធិសញ្ញានេះ។

**ការទទួលស្គាល់**

សេចក្តីត្រូវការ ដើម្បីអនុវត្តយ៉ាងពេញលេញនូវស្តង់ដារនៃកិច្ចព្រមព្រៀង ស្តីពីទិដ្ឋភាពពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (ហៅកាត់ថា "កិច្ចព្រមព្រៀង TRIPS" )

**ការទុកចិត្ត**

ការបង្កើតប្រព័ន្ធ ទទួលស្គាល់សុពលភាព រវាងស្ថាប័ន និងកម្ពុជា គឺដើម្បីផលប្រយោជន៍ទៅវិញទៅមក ហើយ នឹងជួយពង្រឹងការការពារកម្មសិទ្ធិឧស្សាហកម្មនៅកម្ពុជា និងស្របពេលជាមួយគ្នានេះ ធ្វើឲ្យប្រព័ន្ធប្រកាសនីយបត្រតក្កកម្មអឺរ៉ុបមានការទាក់ទាញថែមទៀត។

**បានព្រមព្រៀងគ្នាដូចខាងក្រោមៈ**

## មាត្រា ១
## កម្មវត្ថុនៃកិច្ចព្រមព្រៀង

ភាគីហត្ថលេខី នឹងត្រូវសហការក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀមព្រៀងនេះ ដើម្បីអភិវឌ្ឍឲ្យមានប្រសិទ្ធភាពនូវប្រព័ន្ធទទួលស្គាល់សុពលភាព នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា។

## មាត្រា ២
## ជំនួយផ្នែកបច្ចេកទេស និងជំនួយផ្នែកច្បាប់

ក្នុងទំហំនៃសមត្ថភាពរបស់ខ្លួន ស្ថាប័ននឹងផ្តល់ដល់កម្ពុជា នូវជំនួយផ្នែកបច្ចេកទេស និងជំនួយផ្នែកច្បាប់ ដែលចាំបាច់សម្រាប់អនុវត្តប្រព័ន្ធទទួលស្គាល់សុពលភាព។

## មាត្រា ៣
## កិច្ចសហប្រតិបត្តិការ ផ្នែកច្បាប់ និងរដ្ឋបាល

(១) ភាគីហត្ថលេខីត្រូវផ្លាស់ប្តូរជាប្រចាំនូវព័ត៌មាន អំពីការប្រែប្រួលផ្នែកច្បាប់ ដែលទាក់ទងទៅនឹងប្រព័ន្ធប្រកាសនីយបត្រតក្កកម្មរបស់ខ្លួន។

(២) ប្រសិនបើមានសំណើពីកម្ពុជា ស្ថាប័នត្រូវផ្តល់ការប្រឹក្សាយោបល់តាមការស្នើសុំ ស្របទៅតាមទំហំនៃសមត្ថភាពរបស់ខ្លួន សម្រាប់ការអនុវត្តន៍ ឬការកែប្រែបទប្បញ្ញត្តិផ្នែកច្បាប់ពាក់ព័ន្ធទៅនឹងប្រព័ន្ធប្រកាសនីយបត្រតក្កកម្មរបស់កម្ពុជា។

## មាត្រា ៤

## ដំណើរការនៃការស្នើសុំការទទួលស្គាល់សុពលភាព

(១) EPO ត្រូវទទួលយក រៀបចំដំណើរការ និងបោះពុម្ពផ្សាយ រាល់ពាក្យសុំ ទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា និងត្រូវទំនាក់ទំនងទៅកាន់ MIH នូវព័ត៌មានចាំបាច់ទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធី ចំពោះពាក្យសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងប្រកាសនីយបត្រតក្កកម្មដែលពាក់ព័ន្ធ។

(២) ស្ថិតក្នុងទំហំនៃសមត្ថភាពរបស់ខ្លួន EPO ត្រូវផ្តល់ការប្រឹក្សាដល់ MIH នូវព័ត៌មានសំខាន់ផ្សេងៗទៀត តាមការស្នើសុំ។

## មាត្រា ៥

## ព័ត៌មានពាក់ព័ន្ធទៅនឹងប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

## ដែលត្រូវបានទទួលស្គាល់សុពលភាព

MIH ត្រូវជូនដំណឹងដល់ EPO នូវស្ថានភាពផ្នែកច្បាប់នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាព ជាពិសេស មោឃៈភាព ការអស់សុពលភាព ការបោះបង់ចោល ការកម្រិត ឬការដកហូតយកទៅវិញនៃសំណុំលិខិត។

## មាត្រា ៦

## ផ្នែកហិរញ្ញវត្ថុ

សម្រាប់ការសុំទទួលស្គាល់សុពលភាពនីមួយៗ កម្រៃនៃការទទួលស្គាល់សុពលភាព ត្រូវកំណត់ដោយ EPO ។ ប្រធានរបស់ EPO ត្រូវកំណត់ចំនួនទឹកប្រាក់ដែលត្រូវបង់ ក្នុងការទទួលស្គាល់សុពលភាព និងចំនួនដែលត្រូវរក្សាទុកដោយ EPO ស្របតាមការព្រមព្រៀងរវាង EPO និង MIH។

## មាត្រា ៧

## គណៈកម្មាធិការចម្រុះ និងក្រុមការងារបច្ចេកទេស

(១) គណៈកម្មាធិការចម្រុះនឹងត្រូវបានបង្កើតឡើង ដើម្បីពិភាក្សារាល់បញ្ហាទាំងអស់ដែលកើតឡើងពីកិច្ចព្រមព្រៀងនេះ និងដំណើរការអនុវត្តន៍។ គណៈកម្មាធិការនេះ ត្រូវមានសមាសភាពតំណាងរបស់ EPO និង MIH។ តំណាងការិយាល័យផ្សេងទៀតរបស់រដ្ឋាភិបាលកម្ពុជាដែលពាក់ព័ន្ធ និងដែលទទួលឥទ្ធិពលដោយផ្ទាល់ អាចត្រូវបានប្រឹក្សាយោបល់ លើការអនុវត្តន៍កិច្ចព្រមព្រៀងនេះ។

(២) គណៈកម្មាធិការនេះនឹងជួបប្រជុំគ្នា ក្រោមការផ្តួចផ្តើមដោយរដ្ឋមន្ត្រីរបស់ MIH ឬប្រធានរបស់ EPO។ របៀបវារៈសម្រាប់កិច្ចប្រជុំនីមួយៗ ទីកន្លែង និងកាលបរិច្ឆេទ ត្រូវកំណត់ដោយការព្រមព្រៀងរវាង MIH និង EPO។

(៣) គណៈកម្មាធិការនេះត្រូវពិនិត្យរាល់សកម្មភាព របស់ក្រុមការងារបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងផ្នែកច្បាប់ជាក់លាក់ណាមួយ និងផ្នែកបច្ចេកទេស ដែលកើតឡើងពីការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ៨
## ការអនុវត្តន៍កិច្ចព្រមព្រៀង

(១) កិច្ចការទាំងឡាយណាដែលកើតឡើងដោយភាគីហត្ថលេខី តាមរយៈកិច្ចព្រមព្រៀងនេះ ត្រូវតែអនុវត្តដោយ EPO និង MIH។ EPO អាចប្រគល់កិច្ចការផ្ទាល់របស់ខ្លួន អនុលោមតាមមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ទៅឲ្យការិយាល័យប្រកាសនីយបត្រតក្កកម្ម នៃរដ្ឋដែលជាសមាជិក EPC អាស្រ័យលើការយល់ព្រមរបស់គេ។

(២) សេចក្តីលម្អិតសម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវបានកំណត់ដោយការព្រមព្រៀងគ្នា រវាងរដ្ឋមន្ត្រី MIH និងប្រធាន EPO។

## មាត្រា ៩
## វិសោធនកម្មនៃកិច្ចព្រមព្រៀង

តាមសំណើរបស់ស្ថាប័ន ឬរាជរដ្ឋាភិបាលកម្ពុជា ភាគីហត្ថលេខី ត្រូវធ្វើការចរចាលើការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះ។

## មាត្រា ១០
## រយៈពេល និងការបញ្ចប់កិច្ចព្រមព្រៀង

(១) កិច្ចព្រមព្រៀងនេះនឹងត្រូវបានបញ្ចប់ក្នុងរយៈពេលប្រាំឆ្នាំ ហើយនឹងត្រូវបានបន្តរយៈពេលប្រាំឆ្នាំបន្ថែមទៀត បើពុំនោះទេ លុះត្រាតែភាគីហត្ថលេខី ជំទាស់ជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេលមិនឲ្យលើសពី ប្រាំមួយខែ មុនពេលបញ្ចប់កិច្ចព្រមព្រៀងរយៈពេលប្រាំឆ្នាំ ដែលបានចូលជាធរមាន។

(២) ថ្វីបើមានការចែងក្នុងកថាខណ្ឌ (១)ក៏ដោយ កិច្ចព្រមព្រៀងនេះអាចត្រូវបានបញ្ចប់នៅពេលណាមួយ ដោយមានការស្នើជាលាយលក្ខណ៍អក្សរពីភាគីហត្ថលេខីណាមួយ។

ការបញ្ចប់នៃកិច្ចព្រមព្រៀងនេះនឹងត្រូវមានប្រសិទ្ធភាពក្នុងរយៈមួយឆ្នាំ បន្ទាប់ពីការទទួលបានសេចក្តីជូនដំណឹងនៃការបញ្ចប់ ដោយភាគីហត្ថលេខីណាមួយ បើពុំនោះទេ លុះត្រាតែការជូនដំណឹងខាងលើនេះ បានបញ្ជាក់អំពីរយៈពេលវែងជាង ឬភាគីហត្ថលេខីបានយល់ព្រមលើរយៈពេលខ្លីជាង។

(៣) ប្រសិនបើកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ មាត្រា ៤ ដល់ មាត្រា ៦ នឹងត្រូវបន្តអនុវត្ត ចំពោះពាក្យសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុបណាមួយ និងចំពោះប្រកាសនីយបត្រតក្កកម្មអឺរ៉ុបណាមួយ ដែលការស្នើសុំទទួលស្គាល់សុពលភាព ត្រូវបានដាក់មុនពេលបញ្ចប់កិច្ចព្រមព្រៀង។

**មាត្រា១១**

**ការចូលជាធរមាន**

កាលបរិច្ឆេទចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវបានកំណត់ដោយសេចក្តីជូនដំណឹង រវាង MIH និង EPO បន្ទាប់ពីកម្ពុជាបានអនុម័តនូវបទប្បញ្ញត្តិ ដែលមានចែងក្នុងឯកសារភ្ជាប់នៃ កិច្ចព្រមព្រៀងនេះ។

**មាត្រា ១២**

**អន្តរប្បញ្ញត្តិ**

កិច្ចព្រមព្រៀងនេះមិនត្រូវអនុវត្ត ចំពោះការស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលស្វែងរកការការពារផលិតផលឱសថ រហូតដល់ផុតរយៈអន្តរកាលអនុលោមតាមមាត្រា ៦៦.១ នៃកិច្ចព្រមព្រៀង TRIPS ក៏ដូចជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា TRIPS ស្តីពីការពន្យារពេល នៃរយៈពេលអន្តរកាលដែលអនុញ្ញាតិចំពោះកម្ពុជា។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី........23.........ខែ..January...ឆ្នាំ២០១៧ ធ្វើឡើងជាច្បាប់ដើម ចំនួនពីរច្បាប់ ជាភាសាខ្មែរ ភាសាអង់គ្លេស ភាសាបារាំង និងភាសាអាល្លឺម៉ង់។ ក្នុងករណីមានភាពមិនច្បាស់លាស់ ទំនាស់ ឬ ភាពមិនស្របគ្នា រវាងភាសាទាំងបួន ភាសាអង់គ្លេសត្រូវយកជាគោល សម្រាប់គោលបំណងក្នុងការបកស្រាយ។

| | |
|---|---|
| **ជ.រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** | **ជ.ស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប** |
| **ចម ប្រសិទ្ធ** | **Benoît BATTISTELLI** |
| **ទេសរដ្ឋមន្ត្រី** | **ប្រធានអង្គភាព** |
| **រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** | **ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប** |